N: 8 bis
28-2-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៨ស្ទួន ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

OFFICIAL JOURNAL

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

Oh. Kimpo

LKU

មាតិកា

I . ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

២៤_០២_១៩៩៧_ ព្រះរាជក្រម នស/រម/០២៩៧/០៤ ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧ ៥៧១

២៤_០២_១៩៩៧_ ព្រះរាជក្រម នស/រកម/០២៩៧/០៥ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការលើកទឹកចិត្តវិនិយោគរវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា ៥៧៨

២_ព្រះរាជក្រឹត្យ

២៥_០២_១៩៩៧_ ព្រះរាជក្រឹត្យ នស/រកត/០២៩៧/១៣ ស្តីពីការតែងតាំងលោកឧត្តមសេនីយ៍ត្រី ម៉ា ឈឿន ជាឧកញ៉ា ៥៨១

II _ រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

២៤_០២_១៩៩៧_ អនុក្រឹត្យលេខ ១៥អនក្រ.បក ស្តីពីការបង្កើតមន្ទីរពិសោធន៍សំណង់និងសាធារណការ (ម.ព.ស.ស) ៥៨២

២៤_០២_១៩៩៧_ អនុក្រឹត្យលេខ ១៤ អនក្រ ត.ត ស្តីពីការតែងតាំងផ្លាស់ប្តូរការកិច្ច នាយទាហាន ៥៩៣

២៥_០២_១៩៩៧_ អនុក្រឹត្យលេខ ១៥ អនក្រ.តត ស្តីពីការកែសំរួលឋានន្តរសក្តិនាយទាហាន ៥៩៥

២៥_០២_១៩៩៧_ អនុក្រឹត្យលេខ ១៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៩៦

២៦_០២_១៩៩៧_ អនុក្រឹត្យលេខ ១៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥៩៧

២_សេចក្តីសំរេច

២៤_០២_១៩៩៧_ សេចក្តីសំរេចលេខ ០៩ សសរ ស្តីពីការកែសំរួលសេចក្តីសំរេច
លេខ ៤២សសរ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៦ ៥៩៩

៣_សារាចរ

២៤_០២_១៩៩៧_ សារាចរលេខ ០២ ស.រ ស្តីពីបញ្ហាផ្តល់ពត៌មាន និងបទសម្ភាសន៍
នានា ៦០០

III - ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

២៨_០២_១៩៩៧_ ប្រកាសលេខ ០៥២ ប្រក.សហវ ស្តីពីការតែងតាំងសមាស
ភាពគណៈកម្មការអន្តរក្រសួងដើម្បីធ្វើការវាយតម្លៃលើការប៉ះ
ពាល់ដល់សំណង់ផ្ទះសំបែង និងដីធ្លីប្រជារាស្ត្រ ក្នុងគំរោងសាង
សង់ស្ពាន ឆ្លងកាត់ទន្លេមេគង្គ ក្នុងខេត្តកំពង់ចាម ៦០២

២_ ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

២៤_០២_១៩៩៧_ ប្រកាសលេខ ២១៧ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ហ្គោលឌិន
ដ្យូហ៊្វិនគ្រេឌីង លីមីធិត ផលិតស៊ីម៉ងត៍នៅតំបន់ភ្នំទូកមាសខាងកើត
មានភ្នំតុហាហ្លួង និងភ្នំកូនសត្វស្រុកបន្ទាយមាស ខេត្តកំពត ៦០៤

២៤_០២_១៩៩៧_ ប្រកាសលេខ ២១៨ ឧក.ប្រក អនុញ្ញាតអោយលោក ហេង ងៀប
ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការផលិតគ្រឿងសង្ហារិម ៦០៥

ឥ

២៥_០២_១៩៩៧_ ប្រកាសលេខ ២២០ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ពឺណាស់ ខេមបូឌាហ្គាមែន លីមីធីត (PERNAS CAMBODIA GARMETS LIMITE) តំណាងដោយលោក ABDUL RAHIM BIN BUN YA MIN សញ្ជាតិម៉ាឡេស៊ីបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ទាំងចេញឈ្មោះថា«ពឺណាស់ខេមបូឌា ហ្គាមែនលីមីតធីត» ៦០៦

២៥_០២_១៩៩៧_ ប្រកាសលេខ ២២១ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន សាន់ ហាវ អ៊ិនធឺប្រាយ តំណាងដោយលោក ឡុច សារ៉េត ជនជាតិខ្មែរបង្កើតរោងចក្រផលិតឥដ្ឋការ៉ូសេរាមិច ៦០៧

២៨_០២_១៩៩៧_ ប្រកាសលេខ ២២២ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន សេរាដូកាំបូឌីយ៉ា តំណាងដោយលោក SI BOK PARK សញ្ជាតិកូរ៉េបង្កើតរោងចក្រកាត់ដេរសំពត់ជ័រ (Tent) ៦០៨

២៨_២_១៩៩៧_ ប្រកាសលេខ ២២៣ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន រ៉ុក្ក អាំងទែរណាស្យូណាល់តូបាកកូ តំណាងដោយលោក CHEO TIONG CHOON សញ្ជាតិសង្ហបុរី បង្កើតរោងចក្រផលិតបារី ឈ្មោះរោងចក្រផលិតបារីរ៉ុក្ក អាំងទែរណាស់ស្យូណាល់ ៦០៨

២៨_០២_១៩៩៧_ ប្រកាសលេខ ២២៤ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ហុង អន្តរជាតិ តំណាងដោយលោក ងូវ ស្រ៊ុន ជនជាតិខ្មែរបង្កើតរោងចក្រផលិតបារី ឈ្មោះ «រោងចក្រផលិតបារី ហុង អន្តរជាតិ» ៦០៩

៣_នីស្តីការរដ្ឋមន្ត្រីក្រសួងពតិមាន

ប្រកាស

២៤_០២_១៩៩៧_ ប្រកាសលេខ ០៧៤/៩៧ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៦១០

២៥_០២_១៩៩៧_ ប្រកាសលេខ ០៧៥/៩៧ ពម.ប្រក ស្តីពីការអនុញ្ញាតអោយសារពតិមាន «អន្តរាគមន៍» បន្តការចេញផ្សាយឡើងវិញដោយមានលោក ងួន ថៃដាយ ជាចាងហ្វាងការផ្សាយ ៦១១

២៥_០២_១៩៩៧_ ប្រកាសលេខ ០៧៦/៩៧ ពម.ប្រក អនុញ្ញាតអោយបោះពុម្ពផ្សាយឡើងវិញ និងប្តូរឈ្មោះកាសែតពី «សិរីភេទស្ត្រីខ្មែរ» មកជាបញ្ញាវ័ន្តខ្មែរវិញមានលោក ស៊ុយ ឈុនហាក់ ជាចាងហ្វាង ការផ្សាយ ៦១៣

២៥_០២_១៩៩៧_ ប្រកាសលេខ ០៧៧/៩៧ ពម.ប្រក អនុញ្ញាតអោយកាសែត «សុវណ្ណភូមិ» បន្តការចេញផ្សាយឡើង វិញដោយមានលោក ប៉ុក ចន្ទតារា ជាចាងហ្វាងការផ្សាយ ៦១៤

២៥_០២_១៩៩៧_ ប្រកាសលេខ ០៧៨/៩៧ ពម.ប្រក អនុញ្ញាតអោយបោះពុម្ពផ្សាយ និងប្តូរឈ្មោះពីកាសែត «សង្កេតការណ៍» មកជា «អ្នកសង្កេតការណ៍ថ្មី» មានលោក ស្រី មុនី ហៅ ផលិត ជាចាងហ្វាងការផ្សាយ ៦១៦

៤_ និស្ថ័ការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

ប្រកាស

២៥_០២_១៩៩៧_ ប្រកាសលេខ ១៧១ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យជើងឆ្នុកទៅជាវិទ្យាល័យ ហ៊ុន សែន ជើងឆ្នុក ក្នុងឃុំតាំងក្រសាំង ស្រុកបាធាយ ខេត្តកំពង់ចាម ៦១៨

២៧_០២_១៩៩៧_ ប្រកាសលេខ ១៧៤ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅផែនដីវិទ្យា «សំរាប់សិស្សថ្នាក់ទី ៨» ៦១៩

៥_ និស្ថ័ការក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

២៧_០២_១៩៩៧_ សេចក្តីសំរេចលេខ ៤១/៩៧ កធស អនុញ្ញាតជាគោលការណ៍អោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ ក្រុមមេថូឌិស្ត នៃព្រះវិហាឈ្មោះ «មេថូឌិស្ត ភូមិចំបក់កោង» ឃុំតាសួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ៦២០

ខ

២៧_០២_១៩៩៧_ សេចក្តីសំរេចលេខ ៤២/៩៧ កធស អនុញ្ញាតជាគោលការណ៍ អោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្តធិកាយប្រូតេស្តង់ ក្រុមមេថូឌិស្ទ នៃព្រះវិហារ «មេថូឌិស្ទ ភូមិឫស្សីព្រៃ» ឃុំចំលង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ៦២២

I-ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

ព្រះរាជក្រម នស/រកម/០២៩៧/០៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស–៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤ ៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រមលេខ១១ នស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ ជស-រកម- ០៩៩៥ ០១ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការកែ តម្រូវច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រី ទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៧ ឆាសម័យប្រជុំលើកទី៧ នីតិកាលទី១ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១ .– ត្រូវបានយល់ព្រមតាមការអនុវត្តនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស-៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ១៩៩៥ ។ ការអនុវត្តនេះលេចចេញជាលទ្ធផលដូចខាងក្រោម ÷

កិច្ចប្រតិបត្តិការចំណូល និងចំណាយនៃ ការគ្រប់គ្រង ឆ្នាំ ១៩៩៥ (១)	ច្បាប់ហិរញ្ញវត្ថុ ដើម ឆ្នាំ១៩៩៥	ច្បាប់ហិរញ្ញវត្ថុ កែតំរូវ	ច្បាប់ទូទាត់ ថវិកា
សរុបចំណូល	១.០៥៨.៦០០	១.២៨៣.០០០	១.២៤៣.៧៩៥
សរុបចំណាយ	១.០៥៨.៦០០	១.២៨៣.០០០	១.២៨៩.៤១៦

ចំនួនលើសនៃគណនេយ្យចំណាយ/ចំណូល	-	-	៤៥.៦២១
កិច្ចប្រតិបត្តិការនៃច្បាប់ស្តីពីហិរញ្ញវត្ថុដែលអនុវត្តបានដោយធនាគារជាតិ			
ចំណូលថវិកា	៧០៩.២០០	៩១០.៩០០	៧២៣.៣៨៥
* ចំណូលក្នុងប្រទេសជាប្រចាំ	៥៨១.១០០	៦៩៤.០០០	៦៣៥.៣១៥
* ចំណូលក្នុងប្រទេសជាមូលធន	១២.០០០	១២.៣៨០	៧.៦៦៤
+ ចំណូលក្រៅប្រទេសជាមូលធន	១១៦.១០០	២០៤.៥២០	៨០.៤០៦
ចំណាយថវិកា	៧០៩.២០០	៩១០.៩០០	៧៦៩.០០៦
+ ចំណាយជាប្រចាំ	៦៥២.៧០០	៧៩២.២០០	៦៩២.៣៥៤
+ ចំណាយជាមូលធន	៥៦.៥០០	១១៨.៧០០	៧៦.៦៥៣
កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋដែលអនុវត្តបានក្រៅធនាគារជាតិ			
ចំណូលថវិកា			៦៦.១៩១
+ ចំណូលក្នុងប្រទេសជាប្រចាំ			
+ ចំណូលក្នុងប្រទេសជាមូលធន			
+ ចំណូលក្រៅប្រទេសជាមូលធន			៦៦.១៩១
ចំណាយថវិកា			៦៦.១៩១
+ ចំណាយជាប្រចាំ			៣៩.៣៩១
+ ចំណាយជាមូលធន			២៦.៨០០
វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលបានអនុវត្តក្រៅធនាគារជាតិ			
- ធនធានជាមូលធនសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេស	៣៤៩.៤០០	៣៧២.១០០	៤៥៤.២១៩
-ចំណាយជាមូលធនដោយធនធានសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេស	៣៤៩.៤០០	៣៧២.១០០	៤៥៤.២១៩

(១)សរុបកិច្ចប្រតិបត្តិការចំណូល ចំណាយដែលបានលើកឡើងនេះ មានលក្ខណៈចង្អុលបង្ហាញតែប៉ុណ្ណោះ ពីព្រោះកិច្ចប្រតិបត្តិការនេះ ត្រូវបានអនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេសមិនឆ្លងកាត់ធនាគារជាតិ និងមិនបានចុះកិច្ចបញ្ជីកាក្នុងគណនេយ្យធនាគារជាតិទេ ។

កិច្ចប្រតិបត្តិការនេះគ្រាន់តែជាកម្មវត្ថុនៃការប៉ាន់ប្រមាណតួលេខមួយ ក្រោយពីមានការពិគ្រោះព្រមព្រៀងគ្នាជាមួយអ្នកផ្តល់មូលនិធិ ។ ចំណែកឯចំណាយមួយភាគរបស់ក្រសួងការពារជាតិ និងរដ្ឋបាលស៊ីវិល ក៏មិនបានចុះកិច្ចបញ្ជីកានៅក្នុងគណនេយ្យរតនាគារជាតិដែរ ហើយការចំណាយនេះ ត្រូវបានផ្តល់ហិរញ្ញប្បទានដោយការខ្ចីពីផ្នែកឯកជនខាងក្រៅ និងក្នុងប្រទេស ព្រមទាំងដោយប្រភពធនធានជាតិដែលបានកំណត់ ។

មាត្រា២ .– ចំណូលលំអិតតាមមាតិកាថវិកាត្រូវបានបញ្ជាក់នៅតារាង « ក » ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយលំអិតតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកត្រូវបានបញ្ជាក់នៅតារាង «ខ » ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង «ខ១ » ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ដែលសំរេចបានក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៥ នឹងត្រូវបានបែងចែកតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

ការប៉ាន់ប្រមាណសំរេចបានស្តីពីវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកា និងចំពោះចំណាយត្រូវបានលំអិតតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ហើយត្រូវបានបញ្ជាក់ជាបន្តបន្ទាប់នៅតារាង«ក » និង «ខ »ដូច មានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង « ខ២ » ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសក្រៅរតនាគារជាតិ ដែលសំរេចបានក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៥ និងត្រូវបានបែងចែកតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែលដោយអ្នកផ្តល់បរទេស ។

ជំពូកទី២

បទប្បញ្ញត្តិ ស្តីពីកិច្ចប្រតិបត្តិការថវិកា

មាត្រា ៣ .– ការប្រមូលចំណូល ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទាន អាករ ផលិតផល និងផលទុន ព្រមទាំងការធ្វើអោយសំរេចនូវអំណោយ មូលនិធិ

បដិភាគ និងធនធានបានមកពីការខ្ចី ដែលបានអនុញ្ញាតគ្រោងទុកនៅក្នុងច្បាប់ស្ដីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥

មានចំនួនទឹកប្រាក់សរុប : : ៩១០.៩០០ លានរៀល

–ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់ : ៧២៣.៣៨៥ លានរៀល

–ដូច្នេះមានចំណូលខ្វះចំនួន : ១៨៧.៥១៥ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តដូចតទៅ ÷

–ចំណូលក្នុងប្រទេសជាប្រចាំ	- គំរោងកែតំរូវ	:	៦៩៤.០០០ លានរៀល
	–ការសំរេចបាន	:	៦៣៥.៣១៥ លានរៀល
	–មានចំនួនខ្វះ	:	៥៨.៦៨៥ លានរៀល
–ចំណូលក្នុងប្រទេសជាមូលធន	– គំរោងកែតំរូវ	:	១២.៣៨០ លានរៀល
	–ការសំរេចបាន	:	៧.៦៦៤ លានរៀល
	–មានចំនួនខ្វះ	:	៤.៧១៦ លានរៀល
–ចំណូលក្រៅប្រទេសជាមូលធន	–គំរោងកែតំរូវ	:	២០៤.៥២០ លានរៀល
	–ការសំរេចបាន	:	៨០.៤០៦ លានរៀល
	–មានចំនួនខ្វះ	:	១២៤.១១៤ លានរៀល

មាត្រា ៤ .–ចំណាយចរិកទូទៅរបស់រដ្ឋ ដែលត្រូវទទួលការអនុញ្ញាតតាមច្បាប់ស្ដីពីការកែតំរូវនៃច្បាប់ ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

មានចំនួនទឹកប្រាក់សរុប : ៩១០.៩០០ លានរៀល

–ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់ : ៧៦៩.០០៦ លានរៀល

–ដូច្នេះមានការសន្សំសំចៃឥណទាន ចំនួន : ១៤១.៨៩៤ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តដូចតទៅ ÷

–ចំណាយជាប្រចាំ - គំរោងកែតំរូវ	:	៧៩២.២០០ លានរៀល
–ការសំរេចបាន	:	៦៩២.៣៥៣លានរៀល
–មានការសន្សំសំចៃ ចំនួន	:	៩៩.៨៤៧ លានរៀល
–ចំណាយជាមូលធន - គំរោងកែតំរូវ	:	១១៨.៧០០ លានរៀល

–ការសំរេចបាន : ៧៦.៦៥៣លានរៀល

–មានចំនួនខ្វះ : ៤២.០៤៧ លានរៀល

មាត្រា ៥ .– វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ដែលបានគ្រោងចំណាយនៅក្នុងច្បាប់ ស្តីពីការកែសំរួលនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ មានចំនួន ទឹកប្រាក់សរុប : ៦៦.០០០ លានរៀល

–ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់ : ៥៦.៩៦៣លានរៀល

–ដូច្នេះមានចំនួនខ្វះ : ៩.០៣៧ លានរៀល

មាត្រា ៦ .– ការអនុវត្តកិច្ចប្រតិបត្តិការចំណូល ចំណាយតាមច្បាប់ស្តីពីការកែសំរួលនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលសំរេចបានដោយរតនាគារជាតិ ដូចមានបញ្ជាក់នៅក្នុងមាត្រា៣ និង មាត្រា៤ខាងលើបានបង្ហាញជាលទ្ធផលចុងក្រោយចំណាយលើសចំណូល ដូចតទៅ ÷

– ចំណូលថវិកាដែលសំរេចបានដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ : : ៧២៣.៣៨៥ លានរៀល

–ចំណាយថវិកាដែលសំរេចបានដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ : : ៧៦៩.០០៦ លានរៀល

–ចំនួនលើសនៃ គណនេយ្យចំណាយលើចំណូល : ៤៥.៦២១លានរៀល

ដោយអនុលោមទៅតាមបទប្បញ្ញត្តិក្នុងមាត្រា៥៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ចំនួនលើសនៃគណនេយ្យចំណាយលើចំណូលសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ មានចំនួនទឹកប្រាក់ ៤៥.៦២១ លានរៀល ត្រូវបានកត់ត្រានៅគណនីលទ្ធផល ដែលបានបើកនៅក្នុងគណនេយ្យរតនាគារជាតិ ។

ជំពូកទី៣

បទប្បញ្ញត្តិស្តីពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ ដែលបានអនុវត្តក្រៅរតនាគារជាតិ

មាត្រា៧ .– ត្រូវបានយល់ព្រមតាមការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋក្រៅរតនាគារជាតិ នូវចំណូលដែលសំរេចបាន និងចំណាយដែលបានអនុវត្តលើសពីការអនុញ្ញាតនៃថវិកាទូទៅរបស់រដ្ឋ មានចំនួនទឹកប្រាក់ដូចខាងក្រោមនេះ ÷

សរុបចំណូល	:	៦៦.១៩១ លានរៀល
- ចំណូលក្រៅប្រទេសជាមូលធន	:	៦៦.១៩១ លានរៀល
• អំណោយពិសេសសំរាប់រំលស់បំណុល	:	២៦.៨០០ លានរៀល
• ធនធាននៃការខ្ចីពីបរទេសនៃអង្គការឯកជន(២)	:	៣៩.៣៩១ លានរៀល
សរុបចំណាយ	:	៦៦.១៩១ លានរៀល
• ចំណាយជាប្រចាំ	:	៣៩.៣៩១ លានរៀល
• ចំណាយជាមូលធន	:	២៦.៨០០ លានរៀល

(២) ត្រូវបានយល់ព្រមដោយច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ១៩៩៤ រួចហើយ និងត្រូវបានបញ្ជាក់ដោយច្បាប់ ស្តីពីការកែតំរូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ នៅក្នុងក្របខ័ណ្ឌនៃប្រាក់ខ្ចីពីឯកជនបរទេស ។

ជំពូកទី៤

បទប្បញ្ញត្តិស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារជាតិ

មាត្រា៨.– វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារជាតិ ដែលបានគ្រោងចំណូលចំណាយនៅក្នុងច្បាប់ ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ មានចំនួន ទឹកប្រាក់សរុប : ៣៧២.១០០ លានរៀល

• ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់	:	៤៥៤.២១៩ លានរៀល
• ដូច្នេះមានចំនួនលើស	:	៨២.១១៩ លានរៀល

ជំពូកទី៥

អវសានប្បញ្ញត្តិ

មាត្រា៩ .– បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា ហត្ថលេខា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិ
សម្បទានិងអភិវឌ្ឍន៍និងជារដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

* * *

ព្រះរាជក្រម នស/រកម/០២៩៧/០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស–៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម-០១៩៦-១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំអំពីសម្ដេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសអោយប្រើ

ច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្ដីពីការលើកទឹកចិត្តវិនិយោគរវាងរដ្ឋាភិបាលនៃសហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

ច្បាប់

ស្ដីពី

ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្ដីពីការលើកទឹកចិត្តវិនិយោគ រវាងរដ្ឋាភិបាលនៃសហរដ្ឋអាមេរិកនិងរាជរដ្ឋាភិបាលកម្ពុជា

មាត្រា១ .– អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្ដីពីការលើកទឹកចិត្តវិនិយោគរវាងរដ្ឋាភិបាលនៃ សហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា ដែលធ្វើនៅភ្នំពេញ នាថ្ងៃ ០៤ ខែសីហា ឆ្នាំ១៩៩៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា២ .- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិ

សម្បទានិងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

២_ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស.រកត ០២៩៧-១៣

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ឧត្តមសេនីយ៍ត្រី ម៉ា ឈឿន

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

II - រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

អនុក្រឹត្យ លេខ ១៥ អនក្រ.បក
ស្តីពីការបង្កើតមន្ទីរពិសោធន៍សំណង់ និង
សាធារណការ (ម.ព.ស.ស)

***

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៤ និងព្រះព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកត ១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រម លេខ នស.រកម ១០៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រម លេខ ជស.រកម.០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈរដ្ឋមន្ត្រីយល់ព្រមផង

សំរេច

ជំពូកទី១

បទបញ្ញត្តិទូទៅ

មាត្រា១ : មន្ទីរពិសោធន៍សំណង់ និងសាធារណការ (ម.ព.ស.ស) ត្រូវបានទទួលលក្ខណៈសម្បត្តិជាគ្រឹះស្ថានសាធារណៈមួយមានឧបនិស្ស័យសេដ្ឋកិច្ច តាមន័យរបស់មាត្រា២៦ នៃព្រះរាជក្រម លេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាស សាធារណៈ ។ ម.ព.ស.ស ជានីតិបុគ្គល ប្រកបដោយស្វ័យភាពផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាល បច្ចេកទេស នៃក្រសួងសាធារណការនិងដឹកជញ្ជូន ។

ម.ព.ស.ស ស្ថិតនៅក្រោមឥទ្ធិពលបទបញ្ញត្តិនៃអនុក្រឹត្យនេះ ហើយក្នុងករណីដែលអនុក្រឹត្យនេះពុំបានបញ្ជាក់ ការគ្រប់គ្រងនៃ ម.ព.ស.ស ត្រូវគោរពតាមបទបញ្ញត្តិ នៃព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ព្រមទាំងបទបញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម។

មាត្រា២ : ម.ព.ស.ស មានបេសកកម្ម ÷

- ធ្វើការស្រាវជ្រាវរកបច្ចេកទេសថ្មីៗ សំដៅកែលំអគំរោងសំណង់ទាំងឡាយ ព្រមទាំងចូលរួមក្នុងការតាក់តែងបទដ្ឋានពិសេសសំរាប់ប្រទេសកម្ពុជា ក្នុងវិស័យសិក្សាស្រាវជ្រាវបច្ចេកទេសសំណង់ ។
- ធ្វើការសិក្សាពិសេស ចំពោះមេកានិកដី ចំពោះសំភារៈសំណង់សំរាប់ផលស្រង់ទិន្នន័យចាំបាច់ក្នុងការរៀបចំគំរោងសំដៅទិដ្ឋភាពពីរ គឺសុវត្ថិភាព និងការសន្សំសំចៃ ។

-ត្រួតពិនិត្យគុណភាពសំភារៈសំណង់ និងការប្រើប្រាស់សំភារៈនោះ ។

-តាមដានការងារ មិនត្រឹមតែក្នុងរយៈពេលសាងសង់ទេ ប៉ុន្តែបន្តទៅក្នុងពេលធ្វើអាជីវកម្មប្រើប្រាស់សំណង់ ក្នុងគោលដៅបង្កើនទិន្នផលបច្ចេកទេស ។

-ធ្វើការណែនាំផ្តល់យោបល់ និងផ្តល់ជំនួយបច្ចេកទេស កោសល្យវិច័យ ពិនិត្យការខុសឆ្គង ក្នុងផ្នែកសំណង់ ។

-ធ្វើសហប្រតិបត្តិការ ដើម្បីការបង្ហាត់បង្រៀនបច្ចេកទេសគ្រប់មុខវិជ្ជាទាក់ទិននឹងវិស័យសំណង់ ។

-ទទួលកម្មសិក្សាការី បណ្តុះបណ្តាលអ្នកបច្ចេកទេស រៀបចំថ្នាក់បង្រៀនឯកទេសរួមជាមួយ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។

-រៀបចំឯកសារណាបច្ចេកទេស ដោយប្រមូលផ្តុំនូវទិន្នន័យគ្រប់វិស័យដែលខ្លួនទទួលបានពេលប្រកបសកម្មភាពការងាររបស់ខ្លួន ។

មាត្រា ៣ : ម.ព.ស.ស មានភារកិច្ចទទួលយកមកធ្វើការពិសោធន៍ ការសិក្សា ឬការស្រាវជ្រាវនូវគ្រប់សំណើទាំងអស់ ទោះម្ចាស់សំណើជាឯកជន ឬជាស្ថាប័នសាធារណៈអោយតែសំណើស្របនឹងបេសកកម្ម របស់ខ្លួន ដូចមានចែងក្នុងមាត្រា២ ខាងលើ ។

កិច្ចការទាំងនោះត្រូវគិតជាតំលៃសេវា ដូចដែលមានចែងក្នុងមាត្រា២០ខាងក្រោម ។ បើមានសំណើច្រើន ម.ព.ស.ស ត្រូវអនុវត្តតាមលំដាប់អាទិភាពដែលតំរូវដោយក្រសួងសាធារណការនិងដឹកជញ្ជូន ។

ស្ថាប័នរដ្ឋ និង សហគ្រាសសាធារណៈទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រើប្រាស់ទុនថវិការដ្ឋក្នុងការងារសាងសង់ត្រូវផ្តល់អាទិភាពអោយ ម.ព.ស.ស នូវកិច្ចការពិសោធន៍ ការសិក្សា ការស្រាវជ្រាវដែលចូលទៅក្នុងបរិវេណនៃបេសកកម្ម និងបច្ចេកទេសរបស់ ម.ព.ស.ស ។

មាត្រា៤ : ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ម.ព.ស.ស ត្រូវប្រកាន់គោលការណ៍ និង របៀបប្រកបកិច្ចការដូចគ្នា និង ពាណិជ្ជកម្មទូទៅ ។ ក្នុងន័យនេះ ម.ព.ស.ស ត្រូវទទួលស្វយ័តភាពយ៉ាងធំទូលាយ ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មអោយមានប្រសិទ្ធភាព និងធ្វើយ៉ាងណាអោយបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង់ និងមានការរីកចំរើន ។

មាត្រា ៥ : ម.ព.ស.ស ត្រូវបង់ពន្ធអាករទាំងឡាយស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

ជំពូកទី២

រចនាសម្ព័ន្ធ និងរដ្ឋបាល

មាត្រា៦ : ម.ព.ស.សត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពដូចខាងក្រោម:

- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ១រូប.................. ប្រធាន
- តំណាងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ១រូប.................. សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប.................. - ដ -
- តំណាងសាលាក្រុងភ្នំពេញ ១ រូប.................. - ដ -
- តំណាងសហជីពនៃសហគ្រាសអាគារ និងសាធារណការ ១រូប...... - ដ -
- នាយកសំណង់អាគារ និងនគរូបនីយកម្ម.................. - ដ -
- នាយក ម.ព.ស.ស.................. - ដ -

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវចាំបាច់តែងតាំងដោយអនុក្រឹត្យតាមសំណើនៃក្រសួង ឬ អាជ្ញាធរដែលខ្លួនតំណាងអោយ ។

មាត្រា៧ : សមាជិកក្រុមប្រឹក្សាភិបាល ត្រូវមានសញ្ជាតិខ្មែរ មានសិទ្ធិរដ្ឋប្បវេណីពេញលេញ ពុំដែលទទួលទណ្ឌកម្មមានកំរិតធ្ងន់ពីតុលាការឡើយ ។ លើសពីនេះទៅទៀត សមាជិកក្រុមប្រឹក្សាទាំងនោះ ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីសកម្ម ដែលបានបំរើការយ៉ាងតិច៥ឆ្នាំ ឬក៏ស្បូរជនពុំមែនជាមន្ត្រី រាជការដែលមានអាយុមិនលើសពី៦៥ឆ្នាំ តែមាន[illegible]សេដ្ឋកិច្ច វិទ្យាសាស្ត្រសាងសង់ ។

អាណត្តិសមាជិកក្រុមប្រឹក្សាភិបាល មានថេរវេលា៣ឆ្នាំ ហើយថេរវេលានេះអាចបន្តជាថ្មីទៀតបាន។

ក្នុងការបំពេញអាណត្តិរបស់ខ្លួន សមាជិកក្រុមប្រឹក្សាភិបាល ពុំទទួលការខុសត្រូវផ្ទាល់ខ្លួនម្នាក់ៗ ឬការទទួលខុសត្រូវរួមគ្នាទេ ។ ក្នុងករណីដែលសមាជិកណាម្នាក់មានកំហុសធ្ងន់ធ្ងរ សមាជិករូបនោះអាចត្រូវដកចេញពីមុខងាររបស់ខ្លួនគ្រប់ពេលវេលាដោយអនុក្រឹត្យ ។

មាត្រា៨ : ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាមនៃម.ព.ស.សនិងដើម្បី បំពេញ ឬអនុញ្ញាតលិខិត និងឯកសារគ្រប់ជំពូកទាក់ទងនឹងកម្មវត្ថុរបស់ ម.ព.ស.ស ស្របតាមច្បាប់ជាធរមាន។

ជាអាទិ ក្រុមប្រឹក្សាភិបាលមានភារកិច្ច ÷

១–ផ្តល់ការយល់ព្រមលើគំរោងថវិកាប្រចាំឆ្នាំ សំរាប់ដំណើរការនៃមន្ទីរពិសោធន៍ និង សំរាប់ការវិនិយោគ ស្របតាមកម្មវិធីនៃសកម្មភាព ។

២–ផ្តល់ការយល់ព្រមលើតុល្យការ និងគណនីប្រចាំឆ្នាំ ព្រមទាំងលើរបាយការណ៍ សកម្ម ភាពរបស់សហគ្រាស ។

៣–សំរេចតាមសំណើនៃនាយកទូទៅនូវទំនាក់ទំនង និងបទបញ្ជាផ្ទៃក្នុង ព្រមទាំងលក្ខន្តិកៈ និង តារាងប្រាក់បៀវត្សសំរាប់បុគ្គលិក ដោយគោរពច្បាប់ និងបទបញ្ញត្តិទាំងឡាយជា ធរមាន ។

៤–ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញាដែលចុះដោយសហគ្រាសសាធារណៈ។

៥–កំណត់លក្ខខណ្ឌ និងនីតិវិធីសំរាប់ការទទួលជំនួយបច្ចេកទេសពីអង្គភាពក្នុងស្រុក ឬ បរទេស ។

៦–ផ្តល់ការយល់ព្រមលើកម្មវិធីពហុឆ្នាំ សំរាប់សំភារៈ និងបរិក្ខារ ។

៧–កំណត់តំលៃសេវាកម្ម និងការងារផ្សេងៗ ។

៨–កំណត់កម្មវិធីពហុឆ្នាំ នៃការស្រាវជ្រាវ និងកំណត់ឥណទានសំរាប់ការងារទាំងនេះ ។

៩–អនុញ្ញាតអោយលក់ ទិញ ជួញដូរអចលនទ្រព្យគ្រប់ប្រភេទ ឬភាគហ៊ុន ព្រមទាំង អនុញ្ញាតការខ្ចីបុលអំឡុងកាលមធ្យម ឬវែងដោយ ម.ព.ស.ស ស្របតាមច្បាប់ និងបទបញ្ជាទាំងឡាយជាធរមាន ។

១០–សំរេចបង្កើតបើក បិទការិយាល័យ និងទីភ្នាក់ងារគ្រប់ទីកន្លែងតាមការវិនិយោគ របស់ខ្លួន ។

១១–កំណត់បែបបទនៃការជួយឧបត្ថម្ភដល់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។

មាត្រា៩ : ក្រុមប្រឹក្សាភិបាលបើកប្រជុំរាល់ៗវេលា អាស្រ័យតាមតំរូវការនៃ ម.ព.ស.ស តាម ការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកដែលមានចំនួនបួន (៤) នាក់

យ៉ាងតិចក្នុងចំណោមសមាជិកទាំងអស់ ។ ទោះយ៉ាងណាក៏ដោយកិច្ចប្រជុំត្រូវធ្វើឡើង យ៉ាងតិចម្តងក្នុងរយៈពេល៣ខែ ។

ប្រធានដែលជាប់ឆ្នោត ត្រូវជ្រើសរើសសមាជិកម្នាក់ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល សំរាប់បំពេញភារកិច្ច ជំនួសប្រធានជាបណ្តោះអាសន្ន ។ ក្រុមប្រឹក្សាភិបាលពិភាក្សាលើបញ្ហាទាំងឡាយ ដែលចូលក្នុងក្របខ័ណ្ឌនៃតួនាទីរបស់ខ្លួន ។

មាត្រា១០ : របៀបវារៈ នៃការប្រជុំ ព្រមទាំងឯកសារនានាទាំងឡាយ ត្រូវផ្ញើទៅជូនសមាជិកក្រុម ប្រឹក្សាភិបាលគ្រប់រូបអោយបានយ៉ាងតិច១០ថ្ងៃមុនពេលបើកអង្គប្រជុំ ។

កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តបាន លុះត្រាតែចំនួនសមាជិកវត្តមានក្នុងសម័យប្រជុំនោះ មានចំនួនយ៉ាងតិចពាក់កណ្តាលបូកមួយ នៃចំណោមសមាជិកទាំងអស់ ។ បើសិនជាចំនួនកូរ៉ុម មិនបានគ្រប់ទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំជាថ្មីម្តងទៀត ក្នុងរយៈពេល១៥ថ្ងៃក្រោយ ដើម្បីពិភាក្សាសំរេចឡើងវិញ លើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះមិនទាមទារកូរ៉ុមទេ ។

សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើន នៃសមាជិកវត្តមាននៅក្នុងអង្គប្រជុំ ។ បើសិនការបែកសំលេងមានចំនួនស្មើ ពុំអាចដាច់ស្រេចបាន សំលេងប្រធានមានអាទិភាពលើសំលេងសមាជិកដទៃទៀត ។

មាត្រា១១ : សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និង «មន្ត្រីត្រួតពិនិត្យរដ្ឋ » ព្រមទាំងស្ថាប័នដទៃទៀត ដែលមានចែងក្នុងមាត្រា២៣ ក្នុងរវាង១៥ថ្ងៃយ៉ាងយូរ ចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាលនាសម័យប្រជុំលើកក្រោយ ហើយត្រូវចំលងចូលបញ្ជីដែលមានលេខរៀងទំព័រជាហូរហែ និងមានហត្ថលេខាចំណាំត្រឹមត្រូវ ។ កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាននៃអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលមានវត្តមានក្នុងកិច្ចប្រជុំពេលមុននោះ ។

មាត្រា១២ : ការគ្រប់គ្រងជាប្រក្រតី នៃ ម.ព.ស.ស ត្រូវប្រគល់ទៅនាយកមួយរូប ដែលស្ថិតនៅក្រោមនិវាទនៃក្រុមប្រឹក្សាភិបាល ។ នាយក ម.ព.ស.ស ត្រូវតែងតាំងសំរាប់អាណត្តិ៣ឆ្នាំ ដោយអនុក្រឹត្យ តាមសំណើនៃរដ្ឋមន្ត្រីអាណាព្យាបាល ។

មាត្រា១៣ : ក្រុមប្រឹក្សាភិបាលប្រគល់ជូននាយក នូវអំណាចចាំបាច់សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំ ម.ព.ស.ស ស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះនាយក ÷

១–ជាអ្នករៀបចំសំណុំរឿងទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលសំរេច និងជាអ្នកតាមដានការអនុវត្តន៍រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមកំណត់ពេលនិមួយៗ នាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់ ម.ព.ស.ស ។

២–ទទួលបន្ទុកដឹកនាំម.ព.ស.ស ផ្នែកបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ។

៣–តំណាង ម.ព.ស.ស ចំពោះមុខតតិយជនទាំងឡាយ ក្នុងការបំពេញលិខិតស្នាមស៊ីវិល រដ្ឋបាល ឬលិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និង ការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤–មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ពីការងារ មានសិទ្ធិបញ្ជាត្រួតត្រានូវភ្នាក់ងារ ឬមន្ត្រីគ្រប់រូប ដែលជានិយោជិតរបស់ ម.ព.ស.ស ដោយគោរពតាមបទបញ្ញត្តិលក្ខន្តិកៈបុគ្គលិក តាមច្បាប់ជាធរមាន និង តាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥–មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ ព្រមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅអោយមន្ត្រី ដែលធ្វើការក្រោមនិវាទខ្លួន ស្របតាមល័ក្ខខ័ណ្ឌដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦–ជាសរុប នាយកជាអ្នកអនុវត្តនូវគ្រប់ភារកិច្ច ដែលក្រុមប្រឹក្សាភិបាលប្រគល់អោយ ។

មាត្រា១៤ : លាភការរបស់នាយក និងប្រាក់បំណាច់សំរាប់សមាជិកក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា១៥ : ការចុះ និងការអនុវត្តន៍កិច្ចសន្យាដោយ ម.ព.ស.ស ត្រូវគោរពតាមបែបបទ និងនីតិវិធី ដែលកំណត់ដោយច្បាប់ជាធរមាន ។

ជំពូកទី៣

លក្ខន្តិកៈ នៃបុគ្គលិក

មាត្រា១៦ : ក្រៅពីនាយក បុគ្គលិករបស់ម.ព.ស.ស ស្ថិតនៅក្រោមបទបញ្ញត្តិនៃលក្ខន្តិកៈដោយឡែក មួយដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

ទំរាំមានលក្ខន្តិកៈដោយឡែកនេះ ក្រុមប្រឹក្សាភិបាលត្រូវសំរេចអំពីអន្តរវិធានដែលទាក់ទងនឹងបញ្ហានេះនៅក្នុងកិច្ចប្រជុំលើកទី១របស់ខ្លួនដើម្បីអោយ ម.ព.ស.ស អាចមានដំណើរការ ប្រព្រឹត្តទៅសមស្រប ។

ចាប់ពីពេលដែលលក្ខន្តិកៈដោយឡែកនេះ ចូលជាធរមានបុគ្គលិករបស់ ម.ព.ស.ស លែងមានលក្ខណៈសម្បត្តិជាមន្ត្រីរាជការរបស់រដ្ឋតទៅទៀត ។

បន្ថែមលើបុគ្គលិកអចិន្ត្រៃយ៍ម.ព.ស.ស អាចជ្រើសបុគ្គលិកជាប់កិច្ចសន្យា ឬបុគ្គលិកអណែ្តតដើម្បី បំពេញកិច្ចការដែលមានភាពមិនខ្ជាប់ខ្ជួន ។

ម.ព.ស.ស អាចទទួលនិស្សិតនៃសាលាសាធារណការ និងវិជ្ជាស្ថានបច្ចេកវិទ្យាកម្ពុជា ឬភ្នាក់ងាររាជការដទៃទៀត ជាកម្មសិក្សាការី ។ ភ្នាក់ងារ និងនិស្សិតទាំងនេះ បន្តបើកប្រាក់បៀវត្សពីអង្គភាពដើមរបស់ខ្លួនដដែល ។

ជំពូកទី៤

ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៧ : ម.ព.ស.ស កាន់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធានការនៃគណនេយ្យដែលគេទទួលស្គាល់ជាទូទៅ ។ រយៈការិយបរិច្ឆេទ គណនេយ្យ ចាប់ផ្តើមពីថ្ងៃទី១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ធ្នូ នៃឆ្នាំដដែល ។

តុល្យការ និងគណនីគ្រប់ គ្រងត្រូវកំណត់ទូទាត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់បិទការិយច្ឆេទ ឈរលើរបាយការណ៍ នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

តុល្យការគណនីគ្រប់គ្រងព្រមទាំងរបាយការណ៍ របស់សួងការគណនីត្រូវដាក់សុំការយល់ព្រមអំពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងអំឡុងវេលាមិនលើសពី១៥ថ្ងៃរាប់ពីថ្ងៃ ដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះក៏ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ មិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈ នៃសហគ្រាសសាធារណៈ ។

មាត្រា១៨ : សួងការគណនីត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាលសំរាប់អាណត្តិ២ឆ្នាំ។ ថេរវេលានេះអាចបន្តទៀតបាន ។ ប្រាក់បំណាច់សំរាប់សួងការគណនីត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ហើយត្រូវចាត់ទុកជាចំណាយអាជីវកម្មរបស់ ម.ព.ស.ស ។ សួងការគណនីត្រូវធ្វើរបាយការណ៍មួយ ដើម្បីបញ្ជាក់ថា គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទ មានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាព ពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុ និងបេតិកភណ្ឌរបស់ ម.ព.ស.ស ។

នៅគ្រប់វេលា សួងការ គណនី អាចធ្វើការផែកឆេរ និងការត្រួតពិនិត្យដែលខ្លួនយល់ថា ចាំបាច់គួរតែត្រួតពិនិត្យថែមទាំងអាចទារឯកសារ និង បញ្ជីគណនេយ្យគ្រប់យ៉ាងសំរាប់ធ្វើការត្រួតពិនិត្យ ។ បើការពិនិត្យស្រាវជ្រាវនេះបង្ហាញអោយឃើញភាពមិនត្រឹមត្រូវណាមួយ សួងការគណនីត្រូវរាយការណ៍ភ្លាមជូនប្រធានក្រុមប្រឹក្សាភិបាល ។ សួងការគណនីអាចចូលប្រជុំជាមួយក្រុមប្រឹក្សាភិបាល បានតាមសេចក្តីអញ្ជើញនៃ ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា១៩ : រៀងរាល់ឆ្នាំ មុនថ្ងៃ១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងប្រចាំឆ្នាំ នៃម.ព.ស.ស តាមសំណើរបស់នាយក ហើយបញ្ជូនគំរោងនេះ ដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ គំរោងប្រចាំឆ្នាំនេះ ត្រូវបញ្ជាក់នូវ ÷

១– កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់កម្មវិធីវិនិយោគនេះ ។

២– ថវិកាសំរាប់ដំណើរការនៃម.ព.ស.ស ។

៣– តំលៃផ្តល់សេវាកម្មផ្សេងៗរបស់ម.ព.ស.ស ទៅអតិថិជន ដើម្បីខ្លួនមានលទ្ធភាពទប់ ទល់នឹងសោហ៊ុយ ។

៤–លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ ម.ព.ស.ស ។

ជំពូកទី៥

ធនធានរបស់ ម.ព.ស.ស

មាត្រា ២០: ពេលអនុក្រឹត្យនេះចូលជាធរមាន អាគារម.ព.ស.ស កំពុងប្រើប្រាស់ ត្រូវ... ដើមទុនដំបូង ។ ហើយត្រូវគិតគូរយ៉ាងណាកុំអោយ ម.ព.ស.ស មានឱនភាព ។ ចំណាយសំរាប់ជួសជុល និងថែរក្សាអាគារនេះជាចំណាយប្រក្រតីនៃម.ព.ស.ស ។ ម.ព.ស.ស អាចនឹងទទួលជំនួយពីបរទេសសំរាប់ពង្រឹង និង ពង្រីកដំណើរការអាជីវកម្មរបស់ខ្លួន ។

សំភារៈដែលម.ព.ស.ស កំពុងប្រើប្រាស់ត្រូវកត់ត្រាក្នុងបញ្ជីសារពើភណ្ឌមួយ ហើយទុកជាសម្បត្តិផា... របស់ម.ព.ស.ស ។

ចំណូលប្រ...តិរបស់ម.ព.ស.ស បានមកពីតំលៃសេវា ដែលខ្លួនផ្តល់ អោយអតិថិជន ។ តារាងតំលៃសេវាត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល តាមសំណើរបស់នាយក ។ ហើយត្រូវគិតគូរយ៉ាងណាកុំអោយ ម.ព.ស.ស មានឱនភាព ។

មាត្រា២១ : ម.ព.ស.ស អាចមានគណនីចរន្តក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនី នេះសំរាប់តំរូវការរបស់ខ្លួន ។

មាត្រា២២ : ការខ្ចីបុល អំឡុងកាលមធ្យមឬវែងដោយ ម.ព.ស.ស សំរាប់ប្រើប្រាស់លើចំណាយវិនិយោគ ត្រូវមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី៦

ការទំនាក់ទំនងជាមួយរដ្ឋ

មាត្រា២៣ : ១៥ថ្ងៃយ៉ាងយូរបំផុត ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ម.ព.ស.ស ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ ÷

–កំណត់ហេតុ នៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនីមួយៗ

–គំរោងប្រចាំឆ្នាំ ដូចមានចែងក្នុងមាត្រា ១៩នៃអនុក្រឹត្យនេះ

-របាយការណ៍ ស្ដីពីសកម្មភាព គុណភាព និងគណនីគ្រប់គ្រងទាំងឡាយនៃ ម.ព.ស.ស

-របាយការណ៍ ស្ដីពីការត្រួតពិនិត្យសវនកម្មលើឯកសារ

មាត្រា២៤ : រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្នើរផ្ដល់អាណត្តិតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ ភ្ជាប់អម ម.ព.ស.ស ។ មន្ត្រីរូបនេះ ចូលរួមគ្រប់កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល ហើយអាចផ្ដល់យោបល់លើគ្រប់ចំណុចទាំងឡាយ ដែលមានក្នុងរបៀបវារៈ តែពុំមានសំលេងឆ្នោតទេ ។ «មន្ត្រីត្រួតពិនិត្យរដ្ឋ» បំពេញបេសកកម្មរបស់ខ្លួនអនុលោមតាមបទបញ្ញត្តិ នៃមាត្រា២០ ទៅ២៥ នៃព្រះរាជក្រមលេខ ០៦៩៦/ ០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈរួមទៅនៃសហគ្រាសសាធារណៈ ។

ជំពូកទី៧

អវសានបញ្ញត្តិ

មាត្រា២៥: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងប្រធានស្ថាប័នដែលមានការពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្ថលេខា និងត្រា ហត្ថលេខា និងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

បានយកទទួលថ្វាយ និងជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រីទី១ និង ទី២

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា

ក្រសួងសាធារណការ និងដឹកជញ្ជូន និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា ហត្ថលេខា

អ៊ឹង គៀត **គាត ឈន់**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១៤ អនក្រ.តត

ស្តីពីការ តែងតាំងផ្លាស់ប្តូរភារកិច្ច នាយទាហាន

រាជរដ្ឋាភិបាលកម្ពុជា

* * *

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៣ ស្តីពីការតែ[illegible]ន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃ រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹ[illegible]ថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- យោងតាមសំណើ របស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងផ្លាស់ប្តូរភារកិច្ច ជូននាយទាហានជាន់ខ្ពស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមនេះ ÷

១–លោកវរសេនីយ៍ឯក **អ៊ួន ស៊ីមន្ថា** អត្តលេខ ០០០៤៣១ ពីនាយសេនាធិការកងពលធំលេខ១ ជាមេបញ្ជាការរងកងពលលេខធំ ១

២–លោកវរសេនីយ៍ឯក **ម៉ែន ឆារ៉ាត់** អត្តលេខ០០០៨៦២ពីមេបញ្ជាការរងព្រលានយន្តហោះ កំពង់ឆ្នាំង ជានាយសេនាធិការរង កងអាកាសចរ ខេមរភូមិន្ទ

៣–លោកវរសេនានីយ៍ឯក **យិន យាន** អត្តលេខ ០០០៣៩១ មេបញ្ជាការរង
កងពលធំ លេខ១៤ ជា នាយសេនា
ធិការរង យោធភូមិភាគ៣

៤– លោកវរសេនីយ៍ឯក **ស៊ុម សាឈាស់** អត្តលេខ ០០០៤៥៥ ពីមេបញ្ជាការកងពល
តូចទ័ព ព្រៃទី២ ជា មេបញ្ជាការរង បញ្ជាការ
ដ្ឋានទ័ពពិសេស អគ្គសេនាធិការ

៥– លោកវរសេនីយ៍ឯក **រ័តន គឿន** អត្តលេខ ០០០៣០៩ ពីមេបញ្ជាការរង
បញ្ជាការដ្ឋានកងវិស្វកម្ម ជានាយរងការិ
យាល័យអភិវឌ្ឍន៍ អគ្គសេនាធិការ

៦– លោកវរសេនីយ៍ឯក **គាន់ សារ៉ុម** អត្តលេខ ០០០៤៩៧ ពីជំនួយការទីចាត់ការ
ការងារកលយុទ្ធអគ្គបញ្ជាការ ជា នាយករង
អធិការកិច្ច អគ្គបញ្ជាការ

៧– លោកវរសេនីយ៍ឯក **អ៊ុន គិន** អត្តលេខ ០០០៤៨៩ ពីជំនួយការចលនូបត្ថម្ភ
អគ្គបញ្ជាការ ជានាយរងការិយាល័យអភិវឌ្ឍន៍
អគ្គសេនាធិការ

៨– លោកវរសេនីយ៍ឯក **ជាំ ដារ៉ារិទ្ធ** អត្តលេខ ០០០២៩៣ ពីនាយរង ការិយា
ល័យអភិវឌ្ឍន៍អគ្គសេនាធិការ ជានាយរង
ការិយាល័យទី ៥ អគ្គសេនាធិការ

៩– លោកវរសេនីយ៍ឯក **ម៉ុក ស៊ុនឈួរ** អត្តលេខ ០០០៣៦៧ ពីមេបញ្ជាការ តំបន់
ប្រតិបត្តិការសឹករងកោះកុង ជានាយសេនា
ធិការបញ្ជាការដ្ឋានទ័ពពិសេស

១០– លោកវរសេនីយឯក **ឡូ ដា** អត្តលេខ០០០៣១៥ពីនាយសេនាធិការបញ្ជា
ការដ្ឋានទ័ព ពិសេសជា មេបញ្ជាការ តំបន់
ប្រតិបត្តិការសឹករងកោះកុង

១១–លោកវរសេនានិយឯក **សេង សារៈម៉ឿន** អត្តលេខ០០០៤១១ ពីនាយកសេនាធិការ
កងពលធំលេខ ៦ ទៅជាមន្ត្រីផ្នែកប្រតិបត្តិការ
សិក្សាធិការដ្ឋានទី ៣ អគ្គសេនាធិការ

១២–លោកវរសេនីយឯក **ស៊ុន គីមសឺន** អត្តលេខ០០០៤៩៦ ជាជំនួយការអធិការកិច្ច
អគ្គបញ្ជាការ ជានាយរង នាយកដ្ឋាន
សម្ភារៈបច្ចេកទេស

១៣–លោកវរសេនីយឯក **ស៊ីវុធ ស៊ីលា** អត្តលេខ ០០០៥០០ ពីជំនួយការទីចាត់ការ
កលយុទ្ធ អគ្គបញ្ជាការ ជាជំនួយការឯកឧត្តម
ឧត្តមសេនីយទោ មាស់ សឿម ទីប្រឹក្សា
សម្តេច នាយករដ្ឋមន្ត្រីទី ២

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និង អស់លោកដែលមានឈ្មោះខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះដែលចូលជាធរមាន ចាប់ចាប់ពីថ្ងៃឡាយព្រះហស្ថ លេខានិង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១៥ អនក្រ.តត

ស្តីពីការកែសម្រួល ឋានន្តរសក្តិ នាយទាហាន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃ រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃ កងទ័ពជាតិកម្ពុជា
- យោងតាមសំណើ របស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច.

មាត្រា ១ : ត្រូវបានកែសំរួលឋានន្តរសក្តិ នាយទាហាន ថ្នាក់ វរសេនីយ៍ឯក ក្នុងកងយោធពលខេមរភូមិន្ទ លោក **ស៊ុខ ប៊ុនឆៀន** នាយករងខុទ្ទកាល័យ អគ្គមេបញ្ជាការរង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនាយអគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះព្រះហស្តលេខា និង ព្រះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១៦ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងអប់រំ យុវជននិងកីឡា

សម្រេច

មាត្រា ១ : តែងតាំងលោក **កើ ណៃឈាន** បច្ចុប្បន្នជា អនុប្រធានគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មកជាប្រធានគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១៧ អនក្រ.តត

ស្តីពីការជូនមេដាយ សហមេត្រី

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : ត្រូវបានគ្រល់មេដាយ ធិបឌិន្ទ សហមេត្រីជូនលោកជំទាវ **ស៊ី យូអ៊ី** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជាដែលមានស្នាដៃល្អប្រសើរក្នុងការពង្រឹង និង ពង្រីកទំនាក់ទំនងសហប្រតិបត្តិការ ទ្វេភាគីចិន-កម្ពុជាលើគ្រប់វិស័យ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២_សេចក្ដីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្ដីសំរេចលេខ ០៩ សសរ

ស្ដីពីការកែសំរួលសេចក្ដីសំរេច លេខ ៤២ សសរ

ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៦

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច ព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- តាមតម្រូវការការងារចាំបាច់

សំរេច

ប្រការ ១ : បន្ថែមក្នុងប្រការ ១ នៃសេចក្ដីសំរេចលេខ ៤២ សសរ ចុះថ្ងៃទី ១៧ តុលា ១៩៩៦ នូវ សមាសភាពរបស់គណៈកម្មការចំរុះ សំរាប់ការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ ដូចតទៅ÷ «ឯកឧត្ដមរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជនជាអនុប្រធាន »

ប្រការ ២ : ក្រៅពីនេះ ខ្លឹមសារនៃសេចក្តីសំរេចលេខ ៤២ សសរ ចុះថ្ងៃទី ១៧ តុលា ឆ្នាំ ១៩៩៦ ត្រូវរក្សាទុកជាធរមានដដែល ។

ប្រការ ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងពត៌មាន ប្រធានកាកបាទក្រហមកម្ពុជា ប្រធានមជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា ត្រូវសហការអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

៣_សារាចរ

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សារាចរលេខ ០២ ស.រ

ស្តីពី

បញ្ហាផ្តល់ពត៌មាន និងបទសំភាសន៍នានា

* * *

រាជរដ្ឋាភិបាលបានសង្កេតឃើញថា កន្លងមកក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ធ្លាប់បានផ្តល់ពត៌មាន និងបទសំភាសន៍អំពីការរីកចំរើន ព្រមទាំងគំរោងការអភិវឌ្ឍន៍របស់ក្រសួងស្ថាប័ន និងអង្គភាព របស់ខ្លួនជូនដល់អ្នកកាសែតជាតិនិងអន្តរជាតិធ្វើការផ្សព្វផ្សាយបានលទ្ធផលល្អួមចំណែកលើកស្ទួយដល់ការដឹកនាំរបស់រាជរដ្ឋាភិបាលនិងកិត្យានុភាពជាតិទាំងក្នុងនិងក្រៅប្រទេស។

ប៉ុន្តែក៏នៅមានសេសសល់បញ្ហាខ្លះៗ ដែលកើតចេញពីមន្ត្រីរាជការរបស់ក្រសួង ស្ថាប័ន និង ខេត្តក្រុងខ្លះ ដែលបានធ្វើការផ្តល់ពតិមាន និងបទសំភាសន៍ពុំបានគ្រប់គ្រាន់ និងពុំគ្រប់ជ្រុងជ្រោយ ពិសេសចំពោះស្ថភាពការណ៍នយោបាយយោធា និងជុំវិញបញ្ហាស្វែងរកសន្តិភាព ទាំងស្រុងជូនមាតុប្រទេស ដែលក្នុងនោះ បណ្តាលអោយសាធារណមតិទាំងក្នុងនិងក្រៅប្រទេស មានការភ័ន្តច្រឡំ ចំពោះសភាពការណ៍ពិតរបស់ព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីធានាអោយការផ្តល់ពតិមាន និងបទសំភាសន៍បានច្បាស់លាស់ត្រឹមត្រូវ រាជរដ្ឋាភិបាលសូមធ្វើសេចក្តីណែនាំដល់គ្រប់ក្រសួង ស្ថាប័ន និងខេត្ត ក្រុង ត្រូវចាត់តាំងមន្ត្រីទទួលខុសត្រូវច្បាស់លាស់ ឬ ទាក់ទងជាមួយក្រសួងពតិមាន ដោយប្រើប្រាស់មន្ត្រីពតិមាន តាមក្រសួង ស្ថាប័ន និងខេត្ត ក្រុងដែលមានស្រាប់អោយទទួលភារៈជាអ្នករាយការណ៍ពតិមាន ដល់បណ្តាញឃោសនានានា ហើយខ្លឹមសារត្រូវមានការឯកភាព និងយល់ព្រមពីប្រធានក្រសួង ស្ថាប័ន និងខេត្ត ក្រុងនោះជាមុន ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរខេត្ត ក្រុង ត្រូវខិតខំអនុវត្តតាមខ្លឹមសារណែនាំខាងលើ ដើម្បីធានាអោយការផ្តល់ពតិមាននិងបទសំភាសន៍បានច្បាស់លាស់ ត្រឹមត្រូវ រួមវិភាគទានក្នុងការពង្រឹងកិច្ចការពារសន្តិសុខ ស្ថេរភាពសង្គម និងចូលរួមក្នុងការផ្សះផ្សាជាតិ ដែលកំពុងឈានទៅរកសន្តិ ភាពទាំងស្រុងជូនព្រះរាជាណាចក្រកម្ពុជានៃយើង ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

៦០១

បន្ត
ផ្លូវ
លុង
ការ

ក្រ
រស
ផ្លូវ
ញ
វត្ថុ

ាម
ទឹម
ាតិ

ការងាររបស់ក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៥២ ប្រក.សហវ

ស្តីពីការកំណត់សមាសភាព

គណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការវាយតំលៃលើការប៉ះពាល់

ដល់សំណង់ ផ្ទះសំបែង និង ដីធ្លីប្រជារាស្ត្រ ក្នុងតំរោងសាង

សង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ក្នុងខេត្តកំពង់ចាម

***

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញសេចក្តីសំរេចលេខ ៤៦សសរ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការវាយតំលៃលើការប៉ះពាល់ដល់សំណង់ផ្ទះសំបែង និងដីធ្លីក្នុងតំរោងសាងសាង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ក្នុងខេត្តកំពង់ចាម

- លិខិតលេខ ១០៥.សក.ប្រ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន
- លិខិតលេខ ៦០១/០៥២ កសក.ផសរ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ១៩៩៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួង ដែលមានសមាសភាពដូចខាងក្រោម :

- ឯកឧត្តម **ជា ចេងឈាន** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធាន
- ឯកឧត្តម អភិបាលខេត្ត និង ឯកឧត្តមអភិបាលរងខេត្តរងទី១ ខេត្តកំពង់ចាម សមាជិក
- លោក **សុខ សាមឺន** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- លោក **យី សុខខន** តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក
- លោក **ជា ស៊ីថា** តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក
- លោក **ស៊ុន គឹមស្រ៊ុន** អនុប្រធាននាយកដ្ឋានទុនវិនិយោគ (កសហវ) សមាជិក

ប្រការ ២ : គណៈកម្មការអន្តរក្រសួងនេះត្រូវអនុវត្តភារកិច្ច តាមសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ ៤៦សសរ ចុះថ្ងៃទី ២២ វិច្ឆិកា ឆ្នាំ១៩៩៦ ដើម្បីធ្វើការវាយតំលៃលើការប៉ះពាល់ដល់សំណង់ផ្ទះសំបែង និង ដីធ្លីប្រជារាស្ត្រក្នុងតំរោងសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គក្នុងខេត្តកំពង់ចាម ។

ប្រការ ៣ : ឯកឧត្តម អស់លោកដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និងត្រា
គាត ឈន់

* * *

២_នីតិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ ២១៧ តរ.ប្រក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុនហ្គោលដិន ដូហ្វិន គ្រេនីង លីមីធីតមានអាស័យដ្ឋានផ្ទះលេខ ១៨ B មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ធ្វើអាជីវកម្មនិងប្រើប្រាស់ថ្មកំបោរ ដើម្បីផលិត ស៊ីម៉ងត៍នៅតំបន់ភ្នំទូកមាសខាងកើតដែលរួមមានភ្នំតុហាហ្វ្លង និង ភ្នំកូនសត្វ ស្រុកបន្ទាយមាស ខេត្តកំពត លើផ្ទៃដីសរុបចំនួន ៦៣៧.៧៥ ហិកតា ហើយដែលមានកូអរដោណេដូចតទៅ ÷

ចំណុច	អាប់ស៊ីស	អ័រដោណេ
B :	4 48 ^{50}	II 79 ^{50}
C :	4 51 ^{00}	II 79 ^{50}
D :	4 51 ^{00}	II 77 ^{00}
H :	4 49 ^{75}	II 77 ^{00}
I :	4 49 ^{75}	II 77 ^{25}
j :	4 48 ^{50}	II 77 ^{25}

ប្រការ ២ : ក្រុមហ៊ុនហ្គោលដិន ដូហ្វិន គ្រេនីង លីមីធីត ត្រូវដំណើរការធ្វើអាជីវកម្ម និង ប្រើប្រាស់ថ្មកំបោរដើម្បីផលិតស៊ីម៉ងត៍តាមបរិមាណដែលបានកំណត់ក្នុងគំរោងវិនិយោគរបស់ខ្លួននិង ដោយធានាអនុវត្តតាមលក្ខណៈបច្ចេកទេសអាជីវកម្ម ។

ប្រការ ៣ : ប្រកាសនេះមានតំលៃដល់ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ។ ក្នុងកំឡុងពេល ៩០ ថ្ងៃមុនផុតកំណត់ពេលនៃប្រកាសនេះ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្ម និងប្រើប្រាស់ ថ្មកំបោរ ដើម្បីផលិតស៊ីម៉ង់ត៍បន្ត ។

ប្រការ ៤ : ប្រកាសនេះនឹងត្រូវដកហូតវិញ ក្នុងករណីក្រុមហ៊ុនប្រព្រឹត្តិល្មើសទៅលើលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងធ្វើអាជីវកម្មនិងប្រើប្រាស់ថ្មកំបោរ ឬ កិច្ចព្រមព្រៀងនោះត្រូវបញ្ចប់តាមប្រការ ២៥ នៃកិច្ចព្រមព្រៀង ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ពូ សុធីរៈ

* * *

ប្រកាសលេខ ២១០៨ ឧក.ប្រក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងជាងផលិតគ្រឿងសង្ហារឹម«ហេង ឡៀប»ដែលមានលោក សារឹម ចន្ទណារិទ្ធិ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៩៩០១៨ ភ.ព ចុះថ្ងៃទី ១៥-៧-៩២ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២៤៧ សង្កាត់ទឹកល្អក់ទី ៣ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកដំណើរការ ផលិតកម្មនៅក្នុងទីតាំង ភូមិ ក្បាល អូររាំង ឃុំ សែនមនោរម្យ ស្រុក អូររាំង ខេត្ត មណ្ឌលគិរី ។

ប្រការ ២ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផលព្រមទាំងត្រូវគោរពរាល់ច្បាប់និងបទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៣ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ គ្រោងតុ ទូ កៅអី បង្គោលខ្សែភ្លើង បង្គោលស្ពាន និង ក្តារទ្រុងឡាន ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតផល គឺ ឈើកៅស៊ូ ផ្តៅ និង ដើមឫស្សីដែលមានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៤ : ម្ចាស់រោងជាងត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្មរបស់រោងជាងផ្ញើជូនមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត មណ្ឌលគិរី ។

ប្រការ ៥ : ប្រកាសនេះតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងចក្រត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនិងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ិត ប្រាំង

* * *

ប្រកាសលេខ ២២០ ប្រក.ឧក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ពីណាស់ ខេមបូឌា ហ្គាមែន លីមីធីត (PERNAS CAMBODIA GARMENTS LIMITED) តំណាងដោយលោក (ABDUL RAHIM BIN BUNYA MIN សញ្ជាតិ ម៉ាឡេស៊ី ភេទប្រុសអាយុ ៤៤ ឆ្នាំ អាស័យដ្ឋាន N 15 B JALAN DATO ABDULLAH TAHLR 80300 JOHOR BAHRU JOHOR DARUL TAKZIM MALAYSIA កាន់លិខិតឆ្លងដែនលេខ A7730504 ចុះថ្ងៃទី ២៣.០៦.៩៥ បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ដែលមានឈ្មោះថា ពីណាស់ខេមបូឌាហ្គាមែនលីមីធីតមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៥ ភូមិល្វ សង្កាត់ ស្វាយប៉ាក ខណ្ឌ ឫស្សី កែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតនូវផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាត អោយផលិតនូវផលិតផល សំលៀកបំពាក់ទៅតាមគំរូដែលតំកល់ ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តច្បាប់ ឬ ល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២២១ ប្រក.ឧក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន សាន់ ហាវអ៊ិនធិប្រាយ (SUN HOW ENTERPRISE CO LTD) តំណាងដោយលោក ឡុច សារ៉េត ជនជាតិ ខ្មែរ ភេទប្រុស អាយុ ៤២ ឆ្នាំ អាសយដ្ឋាន ផ្ទះលេខ ២១០ វិថី មហាវិថីព្រះសីហនុ សង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤៦៥៨៦ ភព ចុះថ្ងៃទី ២៥-១១-៩១ បង្កើតរោងចក្រផលិតឥដ្ឋការ៉ូសេរ៉ាមិច ដែលមានឈ្មោះថា រោងចក្រឥដ្ឋការ៉ូ សាន់ ហាវ មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៤ ភូមិទន្ទាប់ខ្ពស់ត្បូង ឃុំដំណាក់អំពិលស្រុកអង្គស្នួល ខេត្តកណ្តាល ។

ប្រការ ២ : ការសាងសង់និងរៀបចំ គ្រឿងចក្រត្រូវធ្វើទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសំរេចក្នុងរយៈពេល ១២ខែ ដោយរាប់បញ្ចូលទាំងរយៈពេលសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុវត្តអោយផលិត ឥដ្ឋការ៉ូសេរ៉ាមិច ទៅតាមគំរូ និងផ្លាកសញ្ញាដែល តំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ហត្ថលេខា និងត្រា

ពូ សុធីរៈ

* * *

ប្រកាសលេខ ២២២ ប្រក.ឧក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុនសេដូ កាំបូឌីយ៉ា (SEDO CAMBODIA C0. LTD) តំណាងដោយលោក SI BOK PARK សញ្ជាតិ កូរ៉េ ភេទប្រុស ២៤ ឆ្នាំ អាស័យដ្ឋាន632-406 HANYANG APT SANGOK-DONG, BUK-KU, INCHON, KOREA កាន់លិខិតឆ្លងដែនលេខ 6860485 ចុះថ្ងៃទី 26.12.95 បង្កើតរោងចក្រកាត់ដេរ សំពត់ជុំ (Tent) នាំចេញ ដែលមានឈ្មោះរោងចក្រកាត់ដេរសេដូកាំបូឌីយ៉ា មានទីតាំងស្ថិតនៅ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាព បង្កើតរោងចក្រកាត់ដេរសំពត់ជុំដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាអោយផលិត "សំពត់ជុំ" ទៅតាមគំរូនិងផ្លាកសញ្ញា ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ផ្ទុយនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២២៣ ប្រក.ឧក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន រ៉ុក អ៊ីង ទែរណាស្យូណាល់តូបាកកូ (ROCK INERNATIONAL TOBACCO) តំណាងដោយលោក CHEO TIONC CHOON សញ្ជាតិ សិង្ហបុរី ភេទប្រុស អាយុ ៤៦ ឆ្នាំ អាស័យដ្ឋាន 39 KINC AIBERT PARK SINGAPORE កាន់លិខិតឆ្លងដែនលេខ S 0092069Z ចុះថ្ងៃទី ២០-០១-៩៣

បង្កើតរោងចក្រផលិតបារី ដែលមានឈ្មោះ រោងចក្រផលិតបារី រ៉ូក អាំងទែរណាស្យូណាល់ មានទីតាំងស្ថិតនៅក្នុងបរិវេណ អតីតរោងចក្រជួសជុលកង់រថយន្ត SKP ផ្លូវលេខ៦៨ សង្កាត់ស្រះចកខណ្ឌដូនពេញរាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាពចក្រផលិតបារីដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិត«បារី»ទៅតាមគំរូ និងផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២២៤ ប្រក.ឧក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ហុង អន្តរជាតិ (HONG INTERNAONAL CO., LTD) តំណាងដោយលោក ង៉ូវ ស្រ៊ុន ជនជាតិ ខ្មែរ ភេទប្រុស អាយុ ២៥ ឆ្នាំ អាស័យដ្ឋាន ផ្ទះលេខ ២៣ បេ ផ្លូវលេខ ៣៣៨ សង្កាត់ទួលស្វាយព្រៃទី ២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណលេខ ១១៤៦៧៧ ភព. ចុះថ្ងៃទី២៩-១២-៩១ បង្កើតរោងចក្រផលិតបារីនាំចេញ ដែលមានឈ្មោះថា រោងចក្រផលិតបារី ហុង អន្តរជាតិ មានទីតាំងស្ថិតនៅ ភូមិត្រពាំងឈូក សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រផលិតបារី ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : ហាងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវផលិតផល «ហារី» នៅតាមគំរូនិងផ្លាកសញ្ញា ដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាស លេខ ០៧៤/៩៧ ពមប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម
- បានឃើញសំណើលេខ ០២០០គខ-កច ចុះថ្ងៃទី ០៣ កុម្ភៈ ១៩៩៧ របស់អភិបាលខេត្តកំពង់ចាម
- យោងតាមការចាំបាច់

– ពិនិត្យលើលក្ខណៈសម្បត្តិនិងសមត្ថភាពមន្ត្រីរាជការ

សម្រេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ០៣នាក់ ថ្នាក់ប្រធានមន្ទីរ និង អនុប្រធានមន្ទីរពត៌មាន ខេត្តកំពង់ចាម នៃ ក្រសួងពត៌មានដូចមានរាយនាមខាងក្រោមនេះ :

១_លោក **ទោង សាត** ប្រធានមន្ទីរពត៌មាន

២_លោក **ជុំ សារិន** អនុប្រធានមន្ទីរពត៌មាន

៣_លោក **ឈុន គង់** អនុប្រធានមន្ទីរពត៌មាន

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ បណ្តាអគ្គនាយកដ្ឋានចំណុះ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យហិរញ្ញវត្ថុ គ្រប់មន្ទីរ ពត៌មានខេត្ត_ ក្រុង និងសាមីខ្លួន ត្រូវអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៧៥/៩៧ ពមប្រក

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រា ៤១

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញច្បាប់ស្តីពីរបបសារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ១៩៩៥

- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ១៦០/៩៤ ពម.សម ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ១៩៩៤ ស្តីពីការអនុញ្ញាតអោយកាសែត «អន្តរាគមន៍» បោះពុម្ពចេញផ្សាយ ដោយមានលោក **គឹម យាន** ជាចាងហ្វាងការផ្សាយ ។
- បានឃើញលិខិតផ្ទេរសិទ្ធិគ្រប់គ្រងរបស់លោក **គឹម យាន** និងលោក **ហុក អាន** ជូនលោក ងួន ថៃដាយ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៧ និងពាក្យសុំបន្តចេញផ្សាយសារពត៌មាន «អន្តរាគមន៍» ឡើងវិញ ចុះថ្ងៃទី ១០ មករា ឆ្នាំ ១៩៩៧ ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយសារពត៌មាន «អន្តរាគមន៍» បន្តចេញផ្សាយឡើងវិញ ដោយមានលោក **ងួន ថៃដាយ** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ៨៦ BE0 ផ្លូវលេខ ២៣៤ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុច ណាមួយក្នុងអត្តសញ្ញាណនៃ កាសែតរបស់ខ្លួនត្រូវជូនដំណឹងជាមុន ០៥ ថ្ងៃមកក្រសួងពត៌មានដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : ប្រកាសលេខ ១៦០/៩៤ ពម.សម ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ១៩៩៤ របស់ក្រសួងពត៌មានស្តីពីការ អនុញ្ញាតអោយសារពត៌មាន «អន្តរាគមន៍» ចេញផ្សាយ និងប្រកាសបិទសារពត៌មាននេះវិញ លេខ ១៩៦/៩៤ ពម ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកសារពត៌មាន ច្បាប់ស្តីពីរបបសារពត៌មាន និងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រួចត្រូវប្រគល់កាសែត ចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : ក្នុងករណីប្រព្រឹត្តល្មើសនឹងសេចក្តី ដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន និងចាងហ្វាងកាសែត « អន្តរាគមន៍ » ត្រូវអនុវត្តន៍ប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៧៦/៩៧ ពមប្រក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រា ៤១
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ កម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស.រក.ម/០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ០៩៥/៩៥ ពម ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការអនុញ្ញាតអោយកាសែត «សម្រែកស្ត្រីខ្មែរ »បោះពុម្ពចេញផ្សាយដោយលោក ហែម ឫទ្ធី ជាចាងហ្វាងការផ្សាយ
- បានឃើញលិខិតស្នើសុំផ្ទេរសិទ្ធិរបស់លោក ហែម ឫទ្ធី ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ជូនទៅលោក **ស៊ុយ ឈុនហាក់** ជាចាងហ្វាងការផ្សាយ និងនិពន្ធនាយកវិញ និង សំណើសុំបោះពុម្ព ឡើងវិញដោយប្តូរឈ្មោះកាសែតពី «សម្រែកស្ត្រីខ្មែរ » មកជា «បញ្ញាវន្តខ្មែរ » របស់លោក ស៊ុយ ឈុនហាក់ ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ១៩៩៧

សម្រេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយឡើងវិញ និងប្តូរឈ្មោះកាសែតពី « សម្រែកស្ត្រីខ្មែរ » មកជា «បញ្ញាវន្តខ្មែរ»វិញដោយមាន ស៊ុយ ឈុនហាក់ ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ៣៣៣ ផ្លូវលេខ ៥៥ ក្រុម ២៥ សង្កាត់បឹងកេងកងទី១ ខ័ណ្ឌ

ចំការមន ក្រុងភ្នំពេញ ។ ក្នុងករណីមានការ ផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណ នៃសារពត៌មានរបស់ខ្លួនត្រូវជូនដំណឹងជាមុន ០៥ ថ្ងៃមកក្រសួងពត៌មាន ដើម្បី...ាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : ប្រកាសលេ... ៩៥/៩៥ ពម. ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការអនុញ្ញាតអោយកាសែត «សម្រែករាស្រ្តខ្មែរ » ចេញផ្សាយ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត ច្បាប់ស្តីពីរបបសារពត៌មាន និងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រួចត្រូវប្រគល់កាសែត ចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : ក្នុងករណីប្រព្រឹត្តល្មើសនឹងសេចក្តី ដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ សាមីខ្លួន ត្រូវទទួល ទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន និងចាងហ្វាងកាសែត « បញ្ញាវន្តខ្មែរ » ត្រូវអនុវត្តន៍ប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៧៧/៩៧ ពមប្រក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រា ៤១
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ កម្ពុជា

- បានឃើញច្បាប់ស្តីពីរបបសារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះ រាជក្រមលេខ ន.ស/រកម/០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ១៣៧/៩៤ ពម. ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពីការអនុញ្ញាតអោយកាសែត «សុវណ្ណភូមិ »បោះពុម្ពចេញផ្សាយ ដោយមានលោក **ម៉ុក ចំនួនតារា** ជាចាងហ្វាងការផ្សាយ និងប្រកាសបិទរបស់ក្រសួងសារពត៌មានលេខ ០៥៣/៩៤ពម.សរ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញសំណើសុំបន្តធ្វើការចេញផ្សាយកាសែត «សុវណ្ណភូមិ » ឡើងវិញ របស់លោក **ម៉ុក ចំនួនតារា** ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

សម្រេច

ប្រការ ១ : អនុញ្ញាតអោយកាសែត «សុវណ្ណភូមិ » បន្តការចេញផ្សាយឡើងវិញ ដោយមានលោក ម៉ុក ចំនួនតារា ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ២៦៧ E1 ផ្លូវលេខ ១៦៣ សង្កាត់ទួលទំពូង២ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុច ណាមួយក្នុងអត្តសញ្ញាណនៃ សារពត៌មានរបស់ខ្លួនត្រូវជូនដំណឹងជាមុន ០៥ ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : ប្រកាសរបស់ក្រសួងពត៌មានលេខ ០៥៣/៩៤ ពម.សរ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពី ការបិទកាសែត «សុវណ្ណភូមិ » ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត ច្បាប់ស្តីពីរបបសារពត៌មាន និងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា Áê<រួចត្រូវប្រគល់កាសែតចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : ក្នុងករណីប្រព្រឹត្តល្មើសនឹងសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ សាមីខ្លួន ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃ ក្រសួងពត៌មាននិងចាងហ្វាង កាសែត « សុវណ្ណភូមិ » ត្រូវអនុវត្តន៍ប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៧៨/៩៧ ពមប្រក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រា ៤១
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ កម្ពុជា ។
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះ រាជក្រមលេខ នស.រកម/០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ៤៨១/៩៣ ឃព.ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការអនុញ្ញាតអោយកាសែត «សង្កេតការណ៍ »បោះពុម្ពផ្សាយ ។
- បានឃើញសំណើសុំរបស់លោក ស្រីមុនីហៅប៊ុន ផលិត បោះពុម្ពផ្សាយនិងប្តូរឈ្មោះកាសែតពី «សង្កេតការណ៍ »មកពី «អ្នកសង្កេតការណ៍ថ្មី » ឡើងវិញ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយ និងប្តូរពីឈ្មោះ «សង្កេតការណ៍»មកជា «អ្នកសង្កេតការណ៍ថ្មី »ឡើងវិញ ដែលមានលោកស្រីមុនី ហៅ ផលិត ជាចាងហ្វាងការផ្សាយ។ ទីស្នាក់ការលេខ ៥៦ ផ្លូវលេខ ៣៤៨ សង្កាត់ទួលស្វាយព្រៃ ២ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរ នូវចំណុចណាមួយក្នុងអត្តសញ្ញាណ នៃការ

សែតរបស់ខ្លួនត្រូវផ្ញើនដំណឹងជាមុន៥ថ្ងៃ មកក្រសួងពត៌មានដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី។

ប្រការ ២ : ប្រកាសលេខ ៤៨១/៩៣ឃព ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៣ ស្តីពីការអនុញ្ញាតអោយកាសែត «សង្កេតការណ៍» បោះពុម្ពផ្សាយត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត ច្បាប់ស្តី ពីរបបសារពត៌មាន និងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រួចត្រូវប្រគល់កាសែតចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : ក្នុងករណីប្រព្រឹត្តល្មើសនឹងសេចក្តី ដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ សាមីខ្លួន ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាននិងចាងហ្វាង កាសែត «អ្នកសង្កេតការណ៍ថ្មី» ត្រូវអនុវត្តន៍ប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៧១ អយក.ប្រក

ស្តីពីការប្តូរឈ្មោះវិទ្យាល័យជើងឆ្នុកទៅវិទ្យាល័យ ហ៊ុន សែន" ជើងឆ្នុក"

ក្នុងឃុំតាំងក្រាំង ស្រុកបាធាយ ខេត្ត កំពង់ចាម

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះ រាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- យោងលិខិតស្នើរបស់គណៈកម្មការទ្រទ្រង់វិទ្យាល័យជើងឆ្នុក ចុះថ្ងៃទី ១០ មករា ១៩៩៧ ដោយមានយោបល់ឯកភាពពីប្រធានមន្ទីរអប់រំយុវជន និងកីឡា និងអភិបាល ខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមធ្យមសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យជើងឆ្នុកបច្ចុប្បន្នទៅជាវិទ្យាល័យ **ហ៊ុន សែន**" ជើងឆ្នុក" ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀង ៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាមាន

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសប្រកាសលេខ ១៧៤ អយក. ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅផែនដីវិទ្យា

" សំរាប់សិស្សថ្នាក់ទី ៨ "

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស.រកត/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាមលេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំយុវជន និងកីឡាស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ

– បានពិនិត្យរបាយការណ៍របស់គណៈកម្មការពិនិត្យខ្លឹមសារសៀវភៅផែនដីវិទ្យាថ្នាក់ទី ៨ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅផែនដីវិទ្យាសំរាប់សិស្សថ្នាក់ទី ៨ ដែលជាស្នាដៃនិពន្ធរបស់ គណៈកម្មការផែនដីវិទ្យា មធ្យមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំយុវជន និងកីឡា និង រៀបរៀងដោយកញ្ញា អ៊ូរ៉ានី ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំណេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានបាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវគ្រឹស្ថានបោះពុម្ពផ្សាយ អប់រំ មជ្ឈមណ្ឌលចែកផ្សាយបណ្ណាល័យ នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា មានភារកិច្ច អនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

តុល ឡោះ

* * *

៥_ឧីស្តីការក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្តីសំរេច លេខ ៤៤/៩៧ ក.ធ.ស

រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦/នស/ ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ. ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំនិង ប្រព្រឹត្តទៅ នៃក្រសួងធម្មការនិងសាសនា
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់ ក្រុមមេថូឌីស្ទ របស់ លោក ម៉ៅ សោភ័ណ្ឌ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តមអភិបាលខេត្តស្វាយរៀង លេខ០៧ សភ. ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៧

សម្រេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនិកាយប្រូតេស្តង់ ក្រុមមេថូឌីស្ទ នៃ ព្រះវិហារឈ្មោះហៅថា «មេថូឌិស្ទ ភូមិចំបក់កោង » មួយកន្លែង ដែលមានទីតាំងស្ថិតនៅ ឃុំ តាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ នៃព្រះវិហារឈ្មោះ «មេថូឌិស្ទ ភូមិចំបក់កោង » ត្រូវអនុញ្ញាតអោយប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ទ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ ព្រះវិហារឈ្មោះ «មេថូឌិស្ទ ភូមិចំបក់កោង »ត្រូវគោរពនិងអនុវត្តអោយបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនង អោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធសន្យាជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និងសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះសាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា-មន្ទីរធម្មការនិងសាសនាខេត្តស្វាយរៀង និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសម្រេចនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ហឿន ចន្ទរ័ត្ន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្តីសម្រេច លេខ ៤២/៩៧ កធស

រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ចស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦/នស/ ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ. ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំនិង ប្រព្រឹត្តទៅ នៃក្រសួងធម្មការនិងសាសនា
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយ ប្រូតេស្តង់ ក្រុមមេថូឌីស្ត របស់ លោក ព្រៀក សំអេង ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៦
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តមអភិបាលខេត្តស្វាយរៀង លេខ ០៨ សកិ. ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនិកាយប្រូតេស្តង់ ក្រុមមេថូឌីស្ទ នៃ ព្រះវិហារឈ្មោះហៅថា «មេថូឌីស្ទ ភូមិឫស្សីព្រៃ » មួយកន្លែង ដែលមាន ទីតាំងស្ថិតនៅ ឃុំ ចម្លង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ។

ប្រការ ២ : សាខាស្នាក់ការ ... បង្គំព្រះគ្រិស្ទ នៃព្រះវិហារឈ្មោះហៅថា «មេថូឌីស្ទភូមិឫស្សីព្រៃ» ត្រូវអនុញ្ញាតអោយប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ទ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ ព្រះវិហារឈ្មោះ «មេថូឌិស្ទ ភូមិឫស្សីព្រៃ »ត្រូវគោរពនិងអនុវត្តអោយបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនង អោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធគ្រប់ជាប់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនានិងសណ្តាប់ធ្នាប់របៀបរៀ... សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តទាំងឡាយ ... ដែលផ្ទុយអំពីសេចក្តីសម្រេចខាងលើនេះសាមីខ្លួនត្រូវទទួលទោស តាមច្បាប់...ធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា-មន្ទីរធម្មការនិងសាសនាខេ... ...រៀង និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវស...ការអនុវត្តន៍សេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសម្រេចនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ឃឿន វណ្ណវុត្ថ

* * *

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល